# មេរៀនទី៦៩៖ ការដាក់តង្វាយរបស់ស្ត្រីមេម៉ាយ

ម៉ាកុស ១២៖ ៤១- ៤៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/3V6wq0mWtLQ

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/b7EMCaO2u9I

**គោលបំណង៖** ចូរថ្វាយដល់ព្រះដោយអំណរ។

**ខគម្ពីរចងចាំ៖ ២កូរិនថូស ៩៖៧** *"ចូរឲ្យគ្រប់គ្នាធ្វើតាមដែលសំរេចក្នុងចិត្តចុះ មិនមែនដោយស្តាយ ឬដោយបង្ខំឡើយ ដ្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ"*។

**ចំរៀង** ( *យូធូបលីង* )៖

១.បើអ្នកសប្បាយក្នុងព្រះយេស៊ូវ https://youtu.be/SsldqdQB-9U

២.ទ្រង់មិនដែលខាន https://youtu.be/uVqBqBENPi4

៣. ទ្រង់ជាសម្បត្តិថ្លៃវិសេស https://youtu.be/u8StIDwyAts

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «នាំកំណាប់ទៅថ្វាយព្រះ»

សម្ភារៈដែលត្រូវការ៖ ស្ករគ្រាប់ និងស្លាបព្រា



១. យើងបែងចែកកុមារជា ២ក្រុម

២.ឲ្យកុមារឈរជាជួរ រួចឲ្យស្ករគ្រាប់ ១៥គ្រាប់ទៅក្រុមនីមួយៗ ហើយឲ្យស្លាបព្រាទៅកុមារម្នាក់មួយៗ

៣.កុមារដំបូងគេត្រូវព្យាយាមចូកស្ករគ្រាប់ ដោយប្រើមាត់របស់ពួកគេ ហើយផ្ទេរស្ករគ្រាប់ នោះទៅឲ្យកុមារដែលឈរបន្ទាប់ពីគេ។ បន្តផ្ទេរស្ករគ្រាប់នោះ ជាបន្តបន្ទាប់គ្នារហូតដល់កុមារចុងក្រោយ ហើយដាក់វាទៅក្នុងចាន។

៤. ក្រុមណាដែលអាចយកស្ករគ្រាប់ដាក់ក្នុងចានបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។ (គ្រូអាចកំណត់ពេលក្នុងការលេងតែ៥នាទីបានហើយ)។

## ៤. ការណែនាំមេរៀន

ព្រះបានប្រទានអំណោយជាច្រើនដល់យើង។ ព្រះគម្ពីរបានប្រាប់យើងថា រាល់អំណោយល្អៗ និងការអស្ចារ្យដែលយើងមាន គឺមកពីព្រះ។ ភាគច្រើនយើងគិតថាអំណោយជារបស់ដែលយើងទិញរុំដោយក្រដាសស្អាត និងផ្តល់ឱ្យក្នុងឱកាសពិសេស។ ប៉ុន្តែក៏មានអំណោយនៃសេចក្តីសប្បុរស និងអំណោយនៃពេលវេលាឬសេចក្តីស្រឡាញ់ផងដែរ។ អំណោយអាចជាអ្វីមួយដែលអ្នកឱ្យទៅមនុស្ស ម្នាក់ដោយសារតែអ្នកដឹងគុណ ឬស្រឡាញ់អ្នកនោះ។ ព្រះរីករាយនឹងផ្តល់អំណោយល្អដល់យើង។ ថ្ងៃនេះយើងនឹង

និយាយអំពីការថ្វាយអំណោយទៅព្រះវិញ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយ ព្រះយេស៊ូវបានយាងទៅសាលាប្រជុំ។ សាលាប្រជុំគឺដូចជាព្រះវិហារមួយក្នុងសម័យព្រះគម្ពីរ អីចឹង។ ព្រះយេស៊ូវអង្គុយនៅកន្លែងដែលព្រះអង្គអាចមើលមនុស្សដាក់តង្វាយ របស់ពួកគេក្នុងប្រអប់តង្វាយបាន។ អ្នកខ្លះដែលព្រះយេស៊ូវបានកត់សម្គាល់គឺជាអ្នកមានដែលមានលុយច្រើន។ ព្រះគម្ពីរបានចែងថា អ្នកមានបានដាក់តង្វាយយ៉ាងច្រើនចូលក្នុងប្រអប់តង្វាយនោះ។

ប៉ុន្តែមានមនុស្សជាច្រើនទៀតនៅឯព្រះវិហារដែលមិនសូវជាមានជីវៈភាពធូរធានោះទេ។ តាមពិតទៅ មានស្ត្រីកំសត់ម្នាក់ដែលប្តីគាត់បានស្លាប់ទៅហើយ។ គាត់គឺជាស្ត្រីមេម៉ាយក្រីក្រម្នាក់។ គាត់មិនមានប្រាក់ច្រើននោះទេ។ ព្រះគម្ពីរបានប្រាប់ថា គាត់មានតែកាក់តូចពីរស្លឹងប៉ុណ្ណោះ។ កាក់ទាំងពីរនេះមានតម្លៃមិនដល់១០០រៀលផង។ នោះជាអ្វីដែលគាត់មានព្រោះគាត់ក្រីក្រខ្លាំងណាស់។ ព្រះយេស៊ូវទតមើលស្ត្រីមេម៉ាយយកកាក់ទាំងពីររបស់គាត់ដាក់ក្នុងប្រអប់តង្វាយនោះ។ ពេលស្ត្រីមេម៉ាយបានដាក់តង្វាយ កាក់ទាំងពីររបស់គាត់រួច នោះគាត់លែងមានប្រាក់ទៀតហើយ។

ព្រះយេស៊ូវទតឃើញតង្វាយរបស់ស្ត្រីមេម៉ាយនោះ ហើយទ្រង់មានព្រះបន្ទូលថា តង្វាយរបស់ស្ត្រីមេម៉ាយប្រសើរ ជាងតង្វាយរបស់អ្នកមានទៅទៀត។ ដ្បិតអ្នកមានគេយករបស់ជាសំណល់ខ្លួនមកថ្វាយ តែស្ត្រីនេះ បានយកពីសេចក្តីកំសត់ខ្លួនមកថ្វាយដល់ព្រះវិញ។ ព្រះមានភាពសំខាន់ណាស់ចំពោះគាត់ ទើបគាត់បានថ្វាយអ្វីៗទាំងអស់ដែលគាត់មានដល់ព្រះអង្គ។ ស្ត្រីមេម៉ាយក្រីក្របានដាក់តង្វាយដល់ព្រះដោយសេចក្តីអំណរ ដោយសារគាត់ស្រឡាញ់ព្រះ។ គាត់មិនចង់កេងប្រវ័ញ្ចអ្វីពីព្រះនោះទេ។ ហើយព្រះពិតជាសព្វព្រះទ័យ ពេលយើងថ្វាយដោយអស់អំពីចិត្ត។

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវនៅឯណានៅថ្ងៃនេះ ហើយតើទ្រង់កំពុងធ្វើអ្វី? *(ទ្រង់នៅឯព្រះវិហារមើលមនុស្ស ថ្វាយតង្វាយ)*

២. តើអ្នកណាបានដាក់ដង្វាយជាលុយច្រើនជាងគេ? *(អ្នកមាន)*

៣. ហេតុអ្វីបានជាព្រះយេស៊ូវមានបន្ទូលថាស្ត្រីមេម៉ាយក្រីក្រ ដែលថ្វាយកាក់តូចពីរស្លឹងប្រសើរជាងគេ? *(ដ្បិតអ្នកមានគេយករបស់ជាសំណល់ខ្លួនមកថ្វាយ តែស្ត្រីនេះ បានយកពីសេចក្តីកំសត់ខ្លួនមកថ្វាយដល់ព្រះវិញ ពីព្រោះគាត់ស្រលាញ់ព្រះ)*

៤. តើយើងគួរមានចិត្តបែបណាពេលយើងថ្វាយដង្វាយដល់ព្រះ? *(អស់ពីចិត្តដោយអំណរ និងអរព្រះគុណដល់ព្រះ )*

## ៧. ល្បែងកំសាន្ត «ស្វែងរកកំណប់»

សម្ភារៈដែលត្រូវការ៖ រង្វាន់សម្រាប់កុមារគ្រប់ៗគ្នា (ស្ករគ្រាប់ ឬនំ)

១. គ្រូត្រូវលាក់កំណប់នោះមុនពេលដែលកុមារមក

២. ឲ្យកុមារគាត់ដើររកកំណប់ដែលលាក់ទុកនោះ ហើយឲ្យពួកគេអាចទុកកំណប់នោះបាន

៣. ព្រះបានប្រទានអំណោយ និងកំណប់ជាច្រើនមកយើង។ យើងគួរតែថ្វាយត្រឡប់ទៅព្រះអង្គវិញដោយចិត្តអំណរ។

### ៨. ខគម្ពីរចងចាំ

**២ កូរិនថូស ៩:៧** *" ចូរឲ្យគ្រប់គ្នាធ្វើតាមដែលសំរេចក្នុងចិត្តចុះ មិនមែនដោយស្តាយ ឬដោយបង្ខំឡើយ ដ្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ"។*

### ៩. ហត្ថកម្ម «កូនជ្រូកសន្សំតង្វាយថ្វាយព្រះជាម្ចាស់»

សូមបោះពុម្ពក្រដាសនៅទំព័រខាងក្រោម។ ការណែនាំគឺនៅលើក្រដាសនោះ។

១. ពន្យល់កុមារថា ពួកគេអាចប្រើកូនជ្រូកសន្សំប្រាក់ដើម្បីថ្វាយតង្វាយដល់ព្រះរៀងរាល់សប្តាហ៍បាន។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវមិនចាប់អារម្មណ៍នឹងទ្រព្យសម្បត្តិដែលយើងមាននោះទេ ដោយសារទ្រង់មើលពីដួងចិត្ត - ដែលជាទ្រព្យសម្បត្តិខាងឯនៃសេចក្តីជំនឿ ការតាំងចិត្ត ចិត្តទូលាយ និងការស្តាប់បង្គាប់។ ទ្រង់ស្គាល់អ្នកពិត។ តើព្រះយេស៊ូវឃើញអ្វីនៅក្នុងដួងចិត្តរបស់អ្នក? តើអ្នកបានដាក់នូវសេចក្តីត្រូវការ ការចង់បាន និងអនាគត របស់អ្នកទៅកាន់ព្រះជាម្ចាស់ហើយឬនៅ? តើអ្នកកំពុងស្ទាក់ស្ទើរឬ? ចូរអង្វរព្រះឲ្យជួយអ្នកលះបង់នូវអ្វីៗទាំងអស់ដែលអ្នកមាននៅចំពោះព្រះដូចស្រ្តីមេម៉ាយនោះដែរ។

# ហត្ថកម្មៈ កូនជ្រូកសន្សំដង្វាយថ្វាយព្រះជាម្ចាស់

១. កាត់ប្រអប់ចេញមក
២. បត់ក្រដាសនោះ ហើយបិត
វាភ្ជាប់គ្នានៅគែមសងខាងឲ្យជាប់
គ្នាដើម្បីបង្កើតជាប្រអប់
៣. ប្រើប្រអប់នោះធ្វើជាប្រអប់
សន្សំដង្វាយថ្វាយព្រះជាម្ចាស់

